សំណើ

# 36 អនុញ្ញាតឱ្យមានការចោទប្រកាន់ពីបទឧក្រិដ្ឋ និងបង្កើនការកាត់ទោសចំពោះឧក្រិដ្ឋកម្មគ្រឿងញៀន និងចោរកម្មមួយចំនួន។ លក្ខន្តិកៈផ្តួចផ្តើម។

**ចំណងជើងផ្លូវការ និងសេចក្តីសង្ខេប** រៀបចំដោយអគ្គព្រះរាជអាជ្ញា

**អត្ថបទស្តីពីវិធានការនេះអាចរកបាននៅទំព័រទី 127 និងនៅលើវិបសាយថ៍រដ្ឋលេខាធិការតាមរយៈ *voterguide.sos.ca.gov*។**

- អនុញ្ញាតឱ្យមានការចោទប្រកាន់បទឧក្រិដ្ឋសម្រាប់ការមានគ្រឿងញៀនមួយចំនួន និងការលួច ទឹកប្រាក់ក្រោមចំនួន $950—ដែលបច្ចុប្បន្នអាចត្រូវចោទប្រកាន់ត្រឹមតែជាបទមជ្ឈិមប៉ុណ្ណោះ—ដោយមានការកាត់ទោសពីករណីនៃការលួច ឬគ្រឿងញៀនពីមុន ដែលអាចអនុវត្តបាន។ ជនជាប់ចោទដែលសារភាពកំហុសចំពោះបទឧក្រិដ្ឋកាន់កាប់គ្រឿងញៀន ហើយការព្យាបាលពេញលេញអាចឈានទៅរកការលុបចោលការចោទប្រកាន់បាន។
- បង្កើនការកាត់ទោសចំពោះឧក្រិដ្ឋកម្មគ្រឿងញៀន និងចោរកម្មដែលបានបញ្ជាក់ផ្សេងទៀត។
- ការបង្កើនទោសដាក់ពន្ធនាគារអាចកាត់បន្ថយការសន្សំសំចៃដែលបច្ចុប្បន្នផ្តល់មូលនិធិដល់សុខភាពផ្លូវចិត្ត និងកម្មវិធីព្យាបាលគ្រឿងញៀន សាលារៀន K–12 និងជនរងគ្រោះពីឧក្រិដ្ឋកម្ម។ ការសន្សំដែលនៅសេសសល់អាចត្រូវបានប្រើប្រាស់សម្រាប់កម្មវិធីព្យាបាលឧក្រិដ្ឋកម្មថ្មី។

## សេចក្តីសង្ខេបនៃការប៉ាន់ប្រមាណរបស់អ្នកវិភាគនីតិបញ្ញត្តិ អំពីផលប៉ះពាល់សារពើពន្ធរបស់រដ្ឋាភិបាលមូលដ្ឋាន និងរដ្ឋ៖

- ការកើនឡើងនៃការចំណាយលើយុត្តិធម៌ព្រហ្មទណ្ឌរបស់រដ្ឋ ដែលទំនងជាមានចាប់ពីរាប់សិបលានដុល្លារដល់កម្រិតទាបជាងរាប់រយលានដុល្លារក្នុងមួយឆ្នាំៗ ជាចម្បងដោយសារតែការកើនឡើងនៃចំនួនមនុស្សនៅក្នុងពន្ធនាគារ។
- ការកើនឡើងនៃការចំណាយលើយុត្តិធម៌ព្រហ្មទណ្ឌក្នុងមូលដ្ឋាន ទំនងជារាប់សិបលានដុល្លារក្នុងមួយឆ្នាំៗ ជាចម្បងដោយសារពន្ធនាគារក្នុងខោនធី ការត្រួតពិនិត្យសហគមន៍ និងសុខភាពផ្លូវចិត្តដែលតម្រូវដោយតុលាការ និងបន្ទុកការព្យាបាលគ្រឿងញៀន។

**ការវិភាគដោយអ្នកវិភាគច្បាប់**

36

## ផ្ទៃខាងក្រោយ

### ការផ្តន្ទាទោសអាស្រ័យលើទម្ងន់ទោសនៃបទឧក្រិដ្ឋ និងប្រវត្តិបទឧក្រិដ្ឋ

***ការផ្តន្ទាទោសចំពោះបទឧក្រិដ្ឋ។*** បទឧក្រិដ្ឋ គឺជាប្រភេទបទឧក្រិដ្ឋធ្ងន់ធ្ងរបំផុតមួយ។ មនុស្សអាចត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារតាមខោនធី ឬពន្ធនាគាររដ្ឋពីបទឧក្រិដ្ឋអាស្រ័យលើបទឧក្រិដ្ឋ និងប្រវត្តិបទឧក្រិដ្ឋរបស់ខ្លួន។ ក្នុងករណីខ្លះ ប្រជាជនអាចត្រូវបានគ្រប់គ្រងនៅក្នុងសហគមន៍ដោយមន្ត្រីទទួលបន្ទុកផ្នែកព្យួរទោសមានលក្ខខណ្ឌប្រចាំខោនធីជំនួសឱ្យការផ្តន្ទាទោសជាប់គុក ឬពន្ធនាគាររយៈពេលខ្លះ ឬទាំងស្រុង។ វិធីនេះត្រូវបានហៅថាការគ្រប់គ្រងរបស់សហគមន៍ខោនធី។ រយៈពេលជាប់ទោសភាគច្រើន អាស្រ័យលើបទឧក្រិដ្ឋ។ ឧទាហរណ៍ ឃាតកម្មអាចត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ 15 ឆ្នាំ ឬច្រើនជាងនេះ។ ផ្ទុយទៅវិញ ការលក់គ្រឿងញៀនអាចត្រូវផ្តន្ទាទោសដាក់គុក ឬជាប់ពន្ធនាគាររហូតដល់ 5 ឆ្នាំ អាស្រ័យលើគ្រឿងញៀន។ ការជាប់ទោសក៏អាចត្រូវបន្ថែមរយៈពេលផងដែរ អាស្រ័យលើព័ត៌មានលម្អិតអំពីបទឧក្រិដ្ឋ។ ឧទាហរណ៍ ការកាត់ទោសការលក់ថ្នាំញៀនមួយចំនួន (ដូចជា ហ្វេតានីល ហេរ៉ូអ៊ីន កូកាអ៊ីន ឬមេតំហ្វេតាមីន) អាចត្រូវបានបន្ថែមរយៈពេលដោយផ្អែកលើចំនួនដែលបានលក់។

***ការផ្តន្ទាទោសចំពោះបទមជ្ឈិម។*** បទមជ្ឈិមគឺជាបទឧក្រិដ្ឋដែលមិនសូវធ្ងន់ធ្ងរ។ ឧទាហរណ៍រួមមានការបំពាន និងការកាន់កាប់គ្រឿងញៀន។ មនុស្សអាចត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារតាមខោនធី

**ការវិភាគដោយ អ្នកវិភាគច្បាប់** 

ស្ថិតក្រោមការឃ្លាំមើលរបស់សហគមន៍តាមខោនធី និង/ឬការផាកពិន័យចំពោះបទមជ្ឈិម។ ទោសអាចជាប់គុករហូតដល់មួយឆ្នាំ។

### សំណើ 47 កាត់បន្ថយការផ្តន្ទាទោសចំពោះអំពើចោរកម្ម និងបទឧក្រិដ្ឋគ្រឿងញៀនមួយចំនួន

នៅក្នុងឆ្នាំ 2014 សំណើ 47 បានផ្លាស់ប្តូរបទល្មើសចោរកម្ម និងគ្រឿងញៀនមួយចំនួនពីបទឧក្រិដ្ឋទៅជាបទមជ្ឈិម។ ឧទាហរណ៍ ការលួចទំនិញ (ដែលមានតម្លៃ $950 ឬតិចជាងនេះពីហាង) និងការកាន់កាប់គ្រឿងញៀនជាទូទៅក្លាយជាបទមជ្ឈិម។

## សំណើ

សំណើ 36 ធ្វើឱ្យមានការផ្លាស់ប្តូរសំខាន់ៗមួយចំនួនទាក់ទងនឹងការដាក់ទណ្ឌកម្មចំពោះការលួច និងបទឧក្រិដ្ឋគ្រឿងញៀន។ ទីមួយ វាបង្កើនការផ្តន្ទាទោសចំពោះបទឧក្រិដ្ឋមួយចំនួន។ ទីពីរ វាបង្កើតនីតិវិធីការតុលាការថ្មីដែលផ្តោតលើការព្យាបាលសម្រាប់បទឧក្រិដ្ឋគ្រឿងញៀនមួយចំនួន។ ទីបី វាទាមទារឱ្យតុលាការព្រមានអ្នកដែលត្រូវបានផ្តន្ទាទោសពីបទលក់ ឬផ្តល់គ្រឿងញៀនខុសច្បាប់ដល់អ្នកដទៃថា ពួកគេអាចត្រូវចោទប្រកាន់ពីបទមនុស្សឃាត ប្រសិនបើពួកគេបន្តធ្វើដូច្នេះ ហើយមាននរណាម្នាក់ស្លាប់។

### បង្កើនការផ្តន្ទាទោសចំពោះអំពើលួច និងបទឧក្រិដ្ឋគ្រឿងញៀនមួយចំនួន

សំណើ 36 បង្កើនការផ្តន្ទាទោសចំពោះអំពើចោរកម្ម និងបទឧក្រិដ្ឋគ្រឿងញៀនមួយចំនួន តាមបីវិធី៖

- ***បង្វែរបទមជ្ឈិមខ្លះទៅជាបទឧក្រិដ្ឋ។*** ឧទាហរណ៍ បច្ចុប្បន្ន ការលួចវត្ថុមានតម្លៃ $950 ឬតិចជាងនេះ ជាទូទៅជាបទមជ្ឈិម។ សំណើ 36 ធ្វើឱ្យបទល្មើសនេះក្លាយជាបទឧក្រិដ្ឋ ប្រសិនបើបុគ្គលនោះធ្លាប់មានការកាត់ទោសពីមុនពីរ ឬច្រើនដងដោយសារបទឧក្រិដ្ឋលួចមួយចំនួន (ដូចជា ការលួចយកទំនិញ ការលួចចូលយកទ្រព្យសម្បត្តិ ឬប្លន់យករថយន្ត)។ ការកាត់ទោសនេះនឹងមានរហូតដល់ទៅបីឆ្នាំនៅក្នុងពន្ធនាគារខោនធី ឬពន្ធនាគាររដ្ឋ។ ការផ្លាស់ប្តូរទាំងនេះដកនូវការកាត់បន្ថយការដាក់ទណ្ឌកម្មមួយចំនួនវិញនៅក្នុងសំណើ 47។
- ***បន្ថែមរយៈពេលជាប់ទោសបទឧក្រិដ្ឋមួយចំនួន។*** ឧទាហរណ៍ សំណើ 36 អនុញ្ញាតឱ្យជាប់ទោសបទឧក្រិដ្ឋពីបទលួច ឬបំផ្លាញទ្រព្យសម្បត្តិត្រូវបន្ថែមរយៈពេលរហូតដល់បីឆ្នាំ ប្រសិនបើមនុស្សបីនាក់ ឬច្រើននាក់បានប្រព្រឹត្តបទឧក្រិដ្ឋជាមួយគ្នា។
- ***តម្រូវឱ្យមានបទឧក្រិដ្ឋមួយចំនួនត្រូវជាប់ពន្ធនាគារ។*** ឧទាហរណ៍ ដូចដែលបានលើកឡើងពីខាងលើស្រាប់ ការកាត់ទោសការលក់ថ្នាំញៀនមួយចំនួន (ដូចជា ហ្វេតានីល ហេរ៉ូអ៊ីន កូកាអ៊ីន ឬមេតំហ្វេតាមីន) អាចត្រូវបានបន្ថែមរយៈរពេលជាប់ទោសដោយផ្អែកលើចំនួនដែលបានលក់។  បច្ចុប្បន្ននេះ ការជាប់ទាំងនេះត្រូវបានធ្វើឡើងនៅក្នុងពន្ធនាគារខោនធី ឬពន្ធនាគាររដ្ឋ អាស្រ័យលើប្រវត្តិបទឧក្រិដ្ឋរបស់បុគ្គលនោះ។ សំណើ 36 ជាទូទៅទាមទារឱ្យមានការជាប់ទោសក្នុងពន្ធនាគារ។

### បង្កើតនីតិវិធីតុលាការថ្មីសម្រាប់ឧក្រិដ្ឋកម្មកាន់កាប់គ្រឿងញៀនមួយចំនួន

សំណើ 36 អនុញ្ញាតឱ្យមនុស្សដែលកាន់កាប់គ្រឿងញៀនខុសច្បាប់ត្រូវបានចោទប្រកាន់ពីបទ “បទឧក្រិដ្ឋដែលកំណត់ឱ្យទទួលយកការព្យាបាល” ជំនួសឱ្យបទមជ្ឈិម ក្នុងករណីខ្លះ។ ជាពិសេស វាអនុវត្តចំពោះអ្នកដែល (1) កាន់កាប់គ្រឿងញៀនមួយចំនួន (ដូចជា ហ្វេតានីល ហេរ៉ូអ៊ីន កូកាអ៊ីន ឬមេតំហ្វេតាមីន) និង (2) ដែលធ្លាប់មានការផ្តន្ទាទោសពីមុនមកពីរឬច្រើនដងពីបទឧក្រិដ្ឋគ្រឿងញៀនមួយចំនួន (ដូចជា កាន់កាប់ ឬលក់គ្រឿងញៀន)។

36

សម្រាប់អត្ថបទពេញស្តីពីសំណើ 36 សូមមើលទំព័រទី 127។

មនុស្សទាំងនេះជាទូទៅនឹងទទួលបានការព្យាបាល ដូចជាសុខភាពផ្លូវចិត្ត ឬការព្យាបាលគ្រឿងញៀន។ អ្នកដែលបញ្ចប់ការព្យាបាល នឹងត្រូវបានលុបចោលការចោទប្រកាន់ចំពោះខ្លួន។ អ្នកដែលមិនបានបញ្ចប់ការព្យាបាល អាចជាប់ពន្ធនាគាររដ្ឋរហូតដល់ 3 ឆ្នាំ។ ការផ្លាស់ប្តូរនេះ មានឥទ្ធិពលលើការកាត់បន្ថយទោសមួយចំនួន នៅក្នុង សំណើ 47។

**ទាមទារឱ្យមានការព្រមានអំពីការចោទប្រកាន់អំពើឃាតកម្មដែលអាចកើតមានសម្រាប់ការលក់ ឬការផ្តល់ថ្នាំញៀន**

សំណើ 36 តម្រូវឱ្យតុលាការព្រមានប្រជាជន ថា ពួកគេអាចត្រូវចោទប្រកាន់ពីបទមនុស្សឃាត ប្រសិនបើពួកគេលក់ ឬចែកចាយថ្នាំញៀនខុសច្បាប់ដែលសម្លាប់នរណាម្នាក់។ ការព្រមាននេះ នឹងត្រូវបានផ្តល់ជូនដល់អ្នកដែលត្រូវបានផ្តន្ទាទោសពីបទលក់ ឬចែកចាយថ្នាំញៀនមួយចំនួន (ដូចជា ហ្វេតានីល ហេរ៉ូអ៊ីន កូកាអ៊ីន និងមេតំហ្វេតាមីន)។ ការធ្វើបែបនេះអាចធ្វើពួកគេទំនងជាត្រូវបានកាត់ទោសពីបទមនុស្សឃាត ប្រសិនបើក្រោយមកពួកគេលក់ ឬចែកចាយថ្នាំញៀនខុសច្បាប់ដល់នរណាម្នាក់ដែលស្លាប់។

36

## ផលប៉ះពាល់សារពើពន្ធ

សំណើ 36 នឹងមានផលប៉ះពាល់សារពើពន្ធផ្សេងៗសម្រាប់រដ្ឋ និងរដ្ឋាភិបាលក្នុងតំបន់។ ទំហំផលប៉ះពាល់ទាំងនេះនឹងអាស្រ័យលើកត្តាមិនច្បាស់លាស់ ដូចជាការសម្រេចចិត្តបែបណាដែលព្រះរាជអាជ្ញាក្នុងតំបន់នឹងធ្វើ។

***បង្កើនការចំណាយលើប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌរបស់រដ្ឋ។*** សំណើ 36 នឹងបង្កើនការចំណាយលើប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌរបស់រដ្ឋតាមវិធីសំខាន់ពីរ។

- ***ការកើនឡើងចំនួនមនុស្សនៅក្នុងពន្ធនាគាររដ្ឋ។*** វានឹងតម្រូវឱ្យមនុស្សមួយចំនួនដែលកំពុងជាប់ទោសនៅថ្នាក់ខោនធី ត្រូវជាប់ទោសក្នុងពន្ធនាគាររដ្ឋ។ ម្យ៉ាងទៀត វាពន្យារពេលជាប់ទោសក្នុងពន្ធនាគារមួយចំនួន។ សរុបមក ចំនួនអ្នកទោសអាចកើនឡើងប្រហែលពីរបីពាន់នាក់។ (ឥឡូវនេះមានមនុស្សប្រហែល 90,000 នាក់នៅក្នុងពន្ធនាគារ។)
- ***ការកើនឡើងនូវបន្ទុកការងាររបស់តុលាការរដ្ឋ។*** នេះក៏ព្រោះតែបទឧក្រិដ្ឋជាធម្មតាចំណាយពេលច្រើនក្នុងការដោះស្រាយជាងបទមជ្ឈិម។ ដូចគ្នាផងដែរ បទឧក្រិដ្ឋដែលកំណត់ឱ្យទទួលយកការព្យាបាលនឹងបង្កើនបន្ទុកការងាររបស់តុលាការ។

សរុបមក សំណើ 36 នឹង **បង្កើនការចំណាយលើប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌរបស់រដ្ឋ ដែលទំនងជាមានចាប់ពីរាប់ម៉ឺនដុល្លារដល់កម្រិតទាបរាប់រយលានដុល្លារក្នុងមួយឆ្នាំ (ប្រចាំឆ្នាំ)**។ ចំនួននេះ គឺតិចជាងពាក់កណ្តាលនៃមួយភាគរយនៃថវិកាមូលនិធិទូទៅសរុបរបស់រដ្ឋ។ (មូលនិធិទូទៅគឺជាគណនីដែលរដ្ឋប្រើដើម្បីបង់ថ្លៃសេវាសាធារណៈភាគច្រើន រួមទាំងការអប់រំ ការថែទាំសុខភាព និងពន្ធនាគារ។)

***បង្កើនការចំណាយលើប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌក្នុងតំបន់។*** សំណើ 36 នឹងបង្កើនការចំណាយលើប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌក្នុងតំបន់តាមវិធីសំខាន់ពីរ។

- ***ការកើនឡើងសុទ្ធនៅក្នុងពន្ធនាគារខោនធី និងចំនួនមនុស្សស្ថិតក្រោមការតាមដានរបស់សហគមន៍។*** នៅក្នុងវិធីមួយចំនួន សំណើ 36 នឹងកាត់បន្ថយចំនួនមនុស្សស្ថិតក្រោមការតាមដាននៅក្នុងគុក និងក្នុងសហគមន៍។ នេះក៏ព្រោះតែអ្នកខ្លះចូលគុករដ្ឋជំនួសថ្នាក់ខោនធី។ នៅក្នុងវិធីផ្សេងទៀត វានឹងបង្កើនចំនួនមនុស្សទាំងនេះផងដែរ។ នេះក៏ព្រោះតែមនុស្សមួយចំនួននឹងចំណាយពេលច្រើនទៀតនៅក្នុងពន្ធនាគារតាមខោនធី ឬស្ថិតក្រោមការតាមដានសហគមន៍។ សរុបមក សំណើ 36 ទំនងជា

## ការវិភាគដោយ អ្នកវិភាគច្បាប់

បន្ត

នឹងបង្កើនចំនួនមនុស្សជាប់ទោសតាមខោនធី។ ការកើនឡើងនេះ អាចមានប្រហែលពីរបីពាន់នាក់។ (ឥឡូវនេះមានអ្នកជាប់ទោសមានប្រហែល 250,000 នាក់នៅថ្នាក់ខោនធី។)

- ***ការកើនឡើងនូវបន្ទុកការងារទាក់ទងនឹងតុលាការក្នុងតំបន់។*** វាក៏នឹងបង្កើនបន្ទុកការងារសម្រាប់ព្រះរាជអាជ្ញាក្នុងតំបន់ និងមេធាវីរដ្ឋផងដែរ។ នេះក៏ព្រោះតែបទឧក្រិដ្ឋ ជាធម្មតាត្រូវចំណាយពេលច្រើនក្នុងការដោះស្រាយជាងបទមជ្ឈិម។ ដូចគ្នានេះផងដែរ បទឧក្រិដ្ឋដែលកំណត់ឱ្យទទួលយកការព្យាបាលនឹងបង្កើតបន្ទុកការងារសម្រាប់ភ្នាក់ងារខោនធីមួយចំនួន (ដូចជាមន្ទីរព្យួរទោសមានលក្ខខណ្ឌ ឬមន្ទីរសុខភាពផ្លូវចិត្ត)។

ជារួម សំណើ 36 នឹង**បង្កើនការចំណាយលើប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌក្នុងតំបន់ទំនងមានចំនួនរាប់សិបលានដុល្លារក្នុងមួយឆ្នាំ។**

***កាត់បន្ថយចំនួនទឹកប្រាក់ដែលរដ្ឋត្រូវចំណាយលើសេវាកម្មមួយចំនួន។*** សំណើ 47 បានបង្កើតនីតិវិធីមួយដែលការសន្សំរបស់រដ្ឋដែលបានប៉ាន់ស្មានពីការកាត់បន្ថយរដាក់ទណ្ឌកម្មរបស់ខ្លួន ត្រូវតែចំណាយទៅលើសុខភាពផ្លូវចិត្ត និងការព្យាបាលគ្រឿងញៀន ការឈប់សម្រាកពីសាលាដោយគ្មានការអនុញ្ញាត និងការបង្ការការបោះបង់ការសិក្សា និងសេវាជនរងគ្រោះ។ ការសន្សំប៉ាន់ស្មានទាំងនេះសរុបទឹកប្រាក់ $95 លានដុល្លារ កាលពីឆ្នាំមុន។ ដោយការលុបចោលផ្នែកទាំងឡាយនៃសំណើ 47, សំណើ 36 កាត់បន្ថយការសន្សំរបស់រដ្ឋពីសំណើ 47។ ការណ៍នេះនឹងកាត់បន្ថយចំនួនទឹកប្រាក់ដែលរដ្ឋត្រូវចំណាយលើសុខភាពផ្លូវចិត្ត និងការព្យាបាលគ្រឿងញៀន ការឈប់សម្រាកពីសាលាដោយគ្មានការអនុញ្ញាត និងការបង្ការការបោះបង់ការសិក្សា និងសេវាជនរងគ្រោះ។ ការកាត់បន្ថយនេះ ទំនងជាមានតម្លៃទាបរាប់សិបលានដុល្លារក្នុងមួយឆ្នាំ។

***ផលប៉ះពាល់សារពើពន្ធផ្សេងទៀត។*** សំណើ 36 អាចមានផលប៉ះពាល់សារពើពន្ធផ្សេងទៀតទៅលើរដ្ឋាភិបាលរបស់រដ្ឋ និងរដ្ឋាភិបាលក្នុងតំបន់។ ឧទាហរណ៍ ប្រសិនបើការបង្កើនការដាក់ទណ្ឌកម្ម ឬការកាត់បន្ថយទំហំបទឧក្រិដ្ឋតាមរយៈការកំណត់ឱ្យទទួលការការព្យាបាល ការចំណាយលើប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌរបស់រដ្ឋ និងក្នុងតំបន់មួយចំនួនអាចត្រូវបានជៀសវាង។ ទោះជាយ៉ាងណា គេមិនដឹងថាតើលទ្ធផលទាំងនេះនឹងអាចកើតមានឬយ៉ាងណានោះទេ។

**សូមចូលទៅកាន់ *sos.ca.gov/campaign-lobbying/cal-access-resources/measure-contributions/2024-ballot-measure-contribution-totals* សម្រាប់បញ្ជី គណៈកម្មាធិការ បង្កើតឡើងជាចម្បងដើម្បីគាំទ្រ ឬប្រឆាំងវិធានការនេះ។**

**សូមចូលទៅកាន់ *fppc.ca.gov/transparency/top-contributors.html* ដើម្បីចូលមើលអ្នកជួយវិភាគទានកំពូលទាំង 10 របស់គណៈកម្មាធិការ។**